ស្ថានទូតអូស្ត្រាលី ភ្នំពេញ

# <u>សេចក្តីប្រកាសព័ត៌មាន</u>

ថ្ងៃទី ៣០ ខែមករា ឆ្នាំ២០១៨

## ការប្រកាសបើកកម្មវិធីអាហារូបករណ៍សម្រាប់ការសិក្សា នៅប្រទេសអូស្ត្រាលីឆ្នាំ២០១៩

នៅថ្ងៃទី ១ ខែកុម្ភៈ ឆ្នាំ២០១៨ ឯកអគ្គរាជទូតអូស្ត្រាលីសម្រាប់កិច្ចការស្ត្រីនិងកុមារី អ្នកស្រីបណ្ឌិត ហ្សាមែន ស្តូន រួមគ្នានឹងលោកជំទាវ អេនជេលឡា ខកខីរ៉េន ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំកម្ពុជា ព្រមទាំងលោកជំទាវវេជ្ជបណ្ឌិត អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី នៃព្រះរាជាណាចក្រកម្ពុជា នឹងរួមគ្នាបើកសម្ពោធជាផ្លូវការនូវកម្មវិធីអាហារូបករណ៍សម្រាប់ការសិក្សានៅប្រទេសអូស្ត្រាលី ឆ្នាំ២០១៩។

អាហារូបករណ៍អូស្ត្រាលី គឺជាអាហារូបករណ៍ដែលមានកិត្យានុភាពលំដាប់អន្តរជាតិ ផ្តល់ដោយរដ្ឋាភិបាលអូស្ត្រាលី សំរាប់អនាគតអ្នកដឹកនាំពិភពលោកជំនាន់ក្រោយ។ អាហារូបករណ៍អូស្ត្រាលីផ្តល់ឱកាសដល់និស្សិតកម្ពុជា ក្នុងការសិក្សាថ្នាក់ក្រោយឧត្តមរួមមាន ថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ និងបណ្ឌិត នៅសកលវិទ្យាល័យនានាក្នុងប្រទេសអូស្ត្រាលី។

អ្នកស្រីបណ្ឌិត ហ្សាមែន ស្តូន មានប្រសាសន៍ថាៈ “ ការទទួលបានការអប់រំ គឺជាផ្នែកមួយដ៏សំខាន់ក្នុងការលើកកម្ពស់អំណាចសេដ្ឋកិច្ច និងភាពជាអ្នកដឹកនាំដល់ស្ត្រី ។”

អ្នកស្រីបណ្ឌិតបន្តទៀតថាៈ “បច្ចុប្បន្ននេះ មួយភាគបីនៃចំនួនអាហារូបករណ៍អូស្ត្រាលី បានផ្តល់ជូនទៅស្ត្រី។ ប៉ុន្តែយើងមានក្តីប្រាថ្នាធំជាងនេះចំពោះកម្មវិធីអាហារូបករណ៍អូស្ត្រាលី និងចំពោះស្ត្រីនៅកម្ពុជាដែលកំពុងស្វែងរកឱកាសបន្តការសិក្សានេះ។ យើងចង់បង្កើនចំនួនស្ត្រីដែលទទួលបានអាហារូប-ករណ៍អោយដល់ ៥០ភាគរយ។”

ចាប់តាំងពីឆ្នាំ១៩៩៤ មក រដ្ឋាភិបាលអូស្ត្រាលីបានឧបត្ថម្ភនិស្សិតកម្ពុជាប្រមាណជា ៧៥០នាក់ ដើម្បីការសិក្សានៅប្រទេសអូស្ត្រាលី តាមរយៈកម្មវិធីអាហារូបករណ៍អូស្ត្រាលី។

លោកជំទាវ អេនជេលឡា ខកខីរ៉េន មានប្រសាសន៍ថាៈ “ អតីតនិស្សិតកម្ពុជាមកពីអូស្ត្រាលីបានធ្វើអោយមានការប្រែប្រួលជាវិជ្ជមាននៅកម្ពុជា។ បន្ទាប់ពីត្រឡប់ពីសិក្សានៅប្រទេសអូស្ត្រាលីវិញ ពួកគេបានចូលបម្រើការក្នុងមុខតំណែងខ្ពស់ៗ ដូចជា រដ្ឋមន្ត្រី មន្ត្រីជាន់ខ្ពស់ក្នុងជួររដ្ឋាភិបាល អ្នកដឹកនាំក្នុងវិស័យការងាររបស់ពួកគេដូចជានាយកប្រតិបត្តិ អ្នកគ្រប់គ្រង អគ្គនាយក និងអ្នកស្រាវជ្រាវជាដើម។”

កម្មវិធីអាហារូបករណ៍អូស្ត្រាលី បើកទទួលពាក្យពីបេក្ខជនដែលមកពីបណ្តាស្ថាប័នរដ្ឋ អង្គការក្រៅរដ្ឋាភិបាល ព្រមទាំងវិស័យឯកជនផងដែរ។ រដ្ឋាភិបាលអូស្ត្រាលីមានការប្តេជ្ញាចិត្តខ្ពស់ក្នុងការផ្តល់ឱកាសដល់មនុស្សគ្រប់គ្នា ហើយយើងសូមលើកទឹកចិត្តជាពិសេសដល់ ស្ត្រី ជនពិការ និងបេក្ខជនដែលមកពីតាមបណ្តាខេត្ត ក្នុងការដាក់ពាក្យ ។

អាហារូបករណ៍អូស្ត្រាលីសំរាប់ឆ្នាំ២០១៩ នឹងបើកទទួលពាក្យចាប់ពី ថ្ងៃទី ១ ខែកុម្ភៈ រហូតដល់ថ្ងៃទី ១៥ ខែមេសា ឆ្នាំ២០១៨។ យើងសូមលើកទឹកចិត្ត ដល់បេក្ខជនដែលចង់សិក្សាលើគ្រប់ផ្នែកទាំងអស់ចូលរួមដាក់ពាក្យសុំអាហារូបករណ៍នេះ។

ព័ត៌មានបន្ថែមអំពីអាហារូបករណ៍អូស្ត្រាលី សូមចូលទៅវេបសាយៈ
www.australiaawardscambodia.org
ទំនាក់ទំនងព័ត៌មានៈ Australian.Embassy.Cambodia@dfat.gov.au